**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អ្នកនាំពាក្យ គ.ជ.ប**

**លេខ ០៥៨ គ.ជ.ប**

ថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តមប្រធាន គ.ជ.ប ៖ ជ្រើសរើសមន្ត្រីដែលមានសមត្ថភាព ឱ្យសមស្របនឹងសមត្ថភាពរបស់មន្ត្រីនោះ

ប្រធាននាយកដ្ឋាន ចំនួន ៤រូប ប្រធានលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ចំនួន ១រូប នាយកខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប ចំនួន ១រូប និងនាយខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប ចំនួន ១រូប ត្រូវបានប្រកាសតែងតាំងឱ្យចូលកាន់តំណែងនៅព្រឹកថ្ងៃពុធ ទី២៤ ខែកក្កដា ឆ្នាំ២០១៩។ ពិធីនេះបានប្រព្រឹត្តទៅនៅសាលសន្និសីទសារព័ត៌មាន គ.ជ.ប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ស៊ិក ប៊ុនហុក** ប្រធាន គ.ជ.ប។

នេះជាលើកទី១ហើយដែលស្ថាប័ន គ.ជ.ប ធ្វើការប្រកាសតែងតាំងប្រធាននាយកដ្ឋាន និងប្រធានលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដោយសារមន្ត្រីមួយចំនួនដែលដល់អាយុចូលនិវត្តន៍ត្រូវបញ្ចប់មុខតំណែង ហើយ គ.ជ.ប បានជ្រើសរើសមន្ត្រីថ្មីមកជំនួសតំណែង ដើម្បីបន្តវេន។

មន្ត្រីថ្មីដែលមកជំនួសតំណែងរួមមាន៖

- លោក **សំ សាវុធ** ជាប្រធាននាយកដ្ឋាន នៅនាយកដ្ឋានប្រតិបត្តិការ
- លោក **វង្ស ចំរើន** ជាប្រធាននាយកដ្ឋាន នៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- លោក **ស៊ុំ ប៊ុនហុង** ជាប្រធាននាយកដ្ឋាន នៅនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត
- លោក **ស៊ិន ដារ៉ា** ជាប្រធាននាយកដ្ឋាន នៅនាយកដ្ឋានរដ្ឋបាល
- លោក **ឌី ភីរុណ** ជាប្រធានលេខាធិការដ្ឋាន នៅលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប
- លោក **កែ រឹទ្ធិ** ជានាយកខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប បន្ថែមលើមុខងារបច្ចុប្បន្ន
- លោក **ជាវង់ សុគារិទ្ធ** ជានាយខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប

អ្នកចូលរួមនៅក្នុងពិធីប្រកាសតែងតាំងនៅថ្ងៃនេះ រួមមាន៖ សមាជិក គ.ជ.ប មន្ត្រីនៃទីស្តីការ គ.ជ.ប ប្រធាន អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតទាំង ២៥ រាជធានី ខេត្ត និងអង្គភាពសារព័ត៌មាន ចំនួន ១០ សរុបចំនួន ១៣៨នាក់ ។

ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តម **ស៊ិក ប៊ុនហុក** បានគូសបញ្ជាក់ថា ហេតុដែលនាំឱ្យមានការផ្លាស់ប្តូរថ្នាក់ដឹកនាំប្រធាននាយកដ្ឋានថ្ងៃនេះ ព្រោះដោយសារច្បាប់។ មន្ត្រីបោះឆ្នោតពីមុនសុទ្ធតែជាមន្ត្រីជាប់កិច្ចសន្យា។

ចាប់តាំងពីមានកំណែទម្រង់ការបោះឆ្នោតនៅឆ្នាំ២០១៥ មក មន្ត្រីបោះឆ្នោតដែលជាថ្នាក់ដឹកនាំនាយកដ្ឋានទាំងនេះជាអ្នករាជការ គ.ជ.ប ហើយឥឡូវដល់អាយុចូលនិវត្តន៍ត្រូវតែចូលនិវត្តន៍ព្រោះច្បាប់កំណត់។ ឯកឧត្តមបានបន្តថា*ការជ្រើសរើស និងតែងតាំងមន្ត្រីដែលមានសមត្ថភាព ឱ្យសមស្របនឹងសមត្ថភាពរបស់មន្ត្រីនោះ (put the right person in the right job)* ហើយការងារនេះ ត្រូវធ្វើឡើងដោយតម្លាភាពបំផុត ដើម្បីពង្រឹងការងារក្នុងវិស័យបោះឆ្នោត។ ឯកឧត្តមក៏បានពន្យល់ និងចែករំលែកបទពិសោធន៍ក្នុងភាពជាអ្នកដឹកនាំផងដែរ ដោយលើកទស្សនៈរបស់លោក **ដាល់ កាណាស៊ី** (Dal Canacy) ថាតើត្រូវធ្វើដូចម្តេចដើម្បីទាក់ទាញទឹកចិត្តអ្នកដទៃ ៖

១. ចូរចាប់អារម្មណ៍ យកចិត្តទុកដាក់ និងស្និទ្ធស្នាលជាមួយអ្នកដទៃ

២. សូមអ្នកមានទឹកមុខញញឹម

៣. ការចងចាំឈ្មោះរបស់មន្ត្រីក្រោមឱវាទ ព្រោះមានសារៈសំខាន់ណាស់ចំពោះគេ

៤. ចូរប្រកាន់ឥរិយាបថស្តាប់មន្ត្រីក្រោមឱវាទនិយាយឱ្យបានច្រើន

៥. ចូរនិយាយជាមួយគូសន្ទនានូវអ្វីដែលគេចូលចិត្ត

៦. ចូរធ្វើយ៉ាងណាឱ្យដៃគូសន្ទនាគិតថាខ្លួនគេមានសារៈសំខាន់។

ហើយគុណសម្បត្តិរបស់មេដឹកនាំល្អ ត្រូវធ្វើដូចម្តេចខ្លះ? ឯកឧត្តមប្រធានក៏បានបង្ហាញគន្លឹះសំខាន់ចំនួន ៩ គឺ៖

១. ការសម្រេចចិត្តដាច់ខាត គឺមេដឹកនាំល្អត្រូវមានការសម្រេចចិត្តដាច់ខាតដោយអាស្រ័យលើហេតុ និងផល

២. មានជំហរច្បាស់លាស់

៣. ស្គាល់ពីវិធីប្រើមនុស្ស

៤. មានភាពស្មោះត្រង់

៥. គាំទ្រកូនចៅ គឺណែនាំចំណុចខ្វះខាត និងគាំទ្រចំណុចខ្លាំង

៦. សិល្បៈក្នុងការចូលរួមក្នុងសង្គម

៧. ស្តាប់មតិយោបល់របស់អ្នកដទៃ

៨. ហ៊ាំហ្វួន គឺធ្វើជាគំរូដល់កូនចៅ

៩. ភាពជាអ្នកដឹកនាំ។

ជាចុងក្រោយឯកឧត្តមប្រធានបានមានប្រសាសន៍ថា គ.ជ.ប នឹងបន្តការងាររៀបចំអ្នកបន្តវេនជាច្រើនផ្សេងទៀតទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់រាជធានី ខេត្ត ដោយសារមន្ត្រីបោះឆ្នោតមួយចំនួនទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់រាជធានី ខេត្ត ដល់អាយុចូលនិវត្តន៍ដែលត្រូវបញ្ចប់មុខតំណែង។ ទាំងអស់នេះជាការពង្រឹងស្ថាប័នបោះឆ្នោតឱ្យទៅជាស្ថាប័នមួយដែលទទួលបានការគាំទ្រ និងទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដូចដែលធ្លាប់ធ្វើនាពេលកន្លងមក៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 959 666<br>Email : hangputhea@gmail.com | ឯកឧត្តម **ឌឹម សុវណ្ណារុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 518 485<br>Email : sovannaromhy@yahoo.fr |